ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤ សសរ

ក្រសួងសុខាភិបាល
ទទួលលិខិតថ្ងៃទី...២០.វិ.០៥
ឆ្នាំ...១១...ម៉ោង.....នាទី
លេខចុះបញ្ជី...៦០២៤...ស.ក

## សេចក្តីសំរេច

### ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃគិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃគិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះដែលមានឈ្មោះ "គណៈកម្មាធិការពិនិត្យវាយតម្លៃគិតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា " ដែលមានសមាសភាពដូចមានខាងក្រោម :

| | |
|---|---|
| ១–ឯកឧត្តម ថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកការងារឧត្តមសិក្សា | ប្រធាន |
| ២–ឯកឧត្តម អគ្គនាយកឧត្តមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ | អនុប្រធាន |
| ៣–ឯកឧត្តម អគ្គនាយក អប់រំ | សមាជិក |
| ៤–លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥–លោក តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៦–លោក តំណាងក្រសួងសុខាភិបាល | សមាជិក |

៧–លោក ប្រធាននាយកដ្ឋានឧត្តមសិក្សា សមាជិក

៨–លោក ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សមាជិក

**ប្រការ២** :–គណៈកម្មាធិការនេះមានភារកិច្ច វាយតម្លៃគិរិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សាក្នុង និងក្រៅប្រទេស តាមសំណើសុំវាយតម្លៃពីបណ្តាស្ថាប័ននានាទូទាំងប្រទេស ។

– កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតម្លៃគិរិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្នុង និងក្រៅប្រទេស ។

**ប្រការ៣** :–គណៈកម្មាធិការមានទីស្នាក់ការក្នុងក្រសួងអប់រំ យុវជន និងកីឡា និងមានសិទ្ធិប្រើប្រាស់ត្រា ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសំរួលការងារ ។

**ប្រការ៤** :–សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងពេលប្រជុំវាយតម្លៃគិរិតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្រសួង ឬ ស្ថាប័នដែលមានការពាក់ព័ន្ធ អាចចាត់តំណាងមកជួយបំភ្លឺ និង ផ្តល់ពត៌មានដែលចាំបាច់បន្ថែម ជូនគណៈកម្មាធិការ ។

**ប្រការ៥** :–គណៈកម្មាធិការ មានសិទ្ធិបង្កើតក្រុមជំនួយការមួយក្រុម ដើម្បីធ្វើជាលេខាធិការ ។

**ប្រការ៦** :–សេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ១៩៩៥ របស់គណៈរដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងបទបញ្ញត្តិនៃសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៧** :–រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមអស់លោក ជាគណៈកម្មាធិការដូចក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

–ខុទ្ទកាល័យព្រះមហាក្សត្រ

–អគ្គលេខាធិការដ្ឋានរដ្ឋសភា

–ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

–ដូចប្រការ ៧

–កាលប្បវត្តិ–ឯកសារ